# បណ្ណព័ត៌មានលេខ 3
## ដំណើរការបញ្ជូនបន្តសម្រាប់ការត្រួតពិនិត្យបណ្ណបើកបរលើកទីពីរ

STATE OF CALIFORNIA DMV Department of Motor Vehicles

### តើអ្នកមានទទួលបានសេចក្តីជូនដំណឹងស្តីពីការបញ្ជូនបន្ត សម្រាប់ការត្រួតពិនិត្យលើកទីពីរ (*Secondary Review Referral Notice, DL 209A*) ដែរឬទេ?

អ្នកទទួលបាន DL 209A ពីព្រោះ ឯកសារអត្តសញ្ញាណ/ឯកសារស្នាក់នៅដែលអ្នកប្រគល់ជូនក្នុងអំឡុងពេលអ្នកទៅកាន់ការិយាល័យមូលដ្ឋាននៃនាយកដ្ឋានយានយន្ត (*Department of Motor Vehicles*, DMV) តម្រូវឲ្យមានការត្រួតពិនិត្យបន្ថែម។ ដើម្បីចាប់ផ្តើមដំណើរការបញ្ជូនបន្តនៃការពិនិត្យមើលលើកទីពីរលើបណ្ណបើកបរ (DL) អ្នកត្រូវតែចូលទៅកាន់ **dmv.ca.gov/SRA** ហៅទូរសព្ទ (855) 421-1001។ ដំណើរការពាក្យសុំ DL មិនអាចបន្តបានទេ រហូតទាល់តែអ្នកដាក់ពាក្យទាក់ទង DMV ដោយប្រើវិធីណាមួយក៏បាន។

### គន្លឹះមានប្រយោជន៍-អ្វីដែលត្រូវដឹងនៅពេលអ្នកទាក់ទង *DMV*

- រង់ចាំ 5 ថ្ងៃធ្វើការបន្ទាប់ពីទទួលបាន DL 209A មុនពេលទាក់ទង DMV និងស្នើសុំការពិនិត្យមើលឡើងវិញ។
- ត្រូវមានវិក្កយបត្រពាក្យសុំបណ្ណបើកបរ (DL) សម្រាប់ជាភស្តុតាង។
- ជំនួយផ្នែកភាសាអាចស្វែងរកបាន។ នៅពេលអ្នកទូរសព្ទ សូមនិយាយថា “ខ្ញុំត្រូវការជំនួយភាសាជាភាសា ____________។”

បន្ទាប់ពីអ្នកទូរសព្ទទៅ DMV អ្នកនឹងទទួលបានសំបុត្រមួយច្បាប់តាមរយៈប្រៃសនីយ៍ និងទីតាំងការិយាល័យដែលអ្នកត្រូវទៅធ្វើការសម្ភាស។

សម្គាល់៖ ប្រសិនបើអ្នកច្រឡំកន្លែង DL 209A សូមទំនាក់ទំនងទៅកាន់ DMV តាមរយៈលេខ 1-800-777-0133 សម្រាប់ជំនួយបន្ថែម។

### តើខ្ញុំរំពឹងចង់បានអ្វីនៅពេលធ្វើបទសម្ភាស?

នៅចុងបញ្ចប់នៃកិច្ចសម្ភាស ឯកសារអត្តសញ្ញាណបណ្ណ/ឯកសារស្នាក់នៅរបស់អ្នកនឹងត្រូវបានគេផ្ទៀងផ្ទាត់ អ្នកនឹងត្រូវបានគេសាកសួរសំណួរមួយចំនួន រួមទាំងថតរូបនៅការិយាល័យមូលដ្ឋានដើម្បីធ្វើការផ្ទៀងផ្ទាត់។ ដំណើរការនៃការសម្ភាសអាចមានរយៈពេលរហូតដល់ ១ ម៉ោង។

ប្រសិនបើឯកសារអត្តសញ្ញាណបណ្ណ/ឯកសារស្នាក់នៅ អាចផ្ទៀងផ្ទាត់បាន អ្នកនឹងទទួលបានលិខិតអង្កេតតាមដានមួយតាមប្រៃសនីយ៍ដែលផ្តល់សេចក្តីណែនាំបន្ថែមអំពីរបៀបបន្តដំណើរការ DL។

### តើឯកសារណាខ្លះដែលខ្ញុំនឹងត្រូវការ?

ឯកសាររបស់អ្នកនឹងត្រូវប្រើប្រាស់ដើម្បីធ្វើការកំណត់ពីអត្តសញ្ញាណរបស់អ្នក និងពីកន្លែងដែលអ្នករស់នៅ។ អ្នកនឹងត្រូវនាំយកមកជាមួយនូវឯកសារមួយចំនួននឹង បញ្ជាក់ពីអត្តសញ្ញាណ/កន្លែងស្នាក់នៅរបស់អ្នក។ ការតម្រូវយកឯកសារទាំងអស់នេះ ជួយការពារភាពត្រឹមត្រូវ និងសុចរិតភាពនៃបណ្ណបើកបើរ (DL) ដែលចេញដោយ DMV និងអាចការពារកុំឲ្យអ្នកដទៃផ្សេងទៀតប្រើប្រាស់ព័ត៌មានរបស់អ្នក និង/ឬអត្តសញ្ញាណរបស់អ្នក។ យកឯកសារមកជាមួយឲ្យបានច្រើនតាមដែលអាចធ្វើទៅបានទៅកាន់ការណាត់ ជួយធ្វើបទសម្ភាសរបស់អ្នក សម្រាប់ឯកសារដែលមាន រៀបរាប់នៅខិត្តបណ្ណនេះ។ រាល់ឯកសារទាំងអស់ដែលបានផ្តល់ជូននឹងត្រូវប្រគល់ជូនវិញទៅកាន់អ្នកបន្ទាប់ពីការសម្ភាររួច។

- ឯកសារសាលារៀនរួមមាន៖
  - — សាលាបឋមសិក្សា
  - — មធ្យមសិក្សា ឯកជនឬរដ្ឋ ឬវិទ្យាស្ថានក្រោយមធ្យមសិក្សា
  - — មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ

ឯកសារសាលារៀនត្រូវមានថ្ងៃខែឆ្នាំកំណើត ឬប្រសិនបើជាឯកសារសាលាបរទេស ត្រូវមានការបោះត្រាដោយសាលា និងមានបិទរូបថតអ្នកដាក់ពាក្យសុំនៅត្រឹមពេលចេញឯកសារនោះ។

- ឯកសារដែលចេញដោយ ឬរក្សាទុកនៅរដ្ឋាភិបាលអាមេរិក ឬរដ្ឋាភិបាលក្នុងសហរដ្ឋអាមេរិក រួមមាន៖
  - — ពាក្យសុំសិទ្ធិជ្រកអាស្រ័យ និងបែបបទដកហូតការដកចេញ (*Application for Asylum and for Withholding of Removal form*, I-589)
  - — វិញ្ញាបនបត្រសិទ្ធិទទួលបានសម្រាប់ស្ថានភាពសិស្សមិនមែនអន្តោប្រវេសន៍ (*Certificate of Eligibility for Non-immigrant Student Status*, F-1 ឬ M-1)
  - — វិញ្ញាបនបត្រសិទ្ធិទទួលបានសម្រាប់ស្ថានភាពសិស្សជាភ្ញៀវផ្លាស់ប្តូរចំណេះដឹង (*Certificate of Eligibility for Exchange Visitor Status*, J-1)
  - — ឯកសារតុលាការដែលមានឈ្មោះរបស់អ្នកជាភាគីម្ខាងនៃនីតិវិធីតុលាការ
  - — លិខិតប្រកាសពន្ធប្រាក់ចំណូល
  - — បណ្ណបើកបរ (មានសុពលភាព ឬអស់សុពលភាព)

- ស្ថានភាពគ្រួសារ រួមមាន៖
  - សំបុត្រអាពាហ៍ពិពាហ៍
  - លិខិតចុះបញ្ជីដៃគូ

ភាសានៅលើបណ្ណបើកបរ (ក្រៅពីភាសាអង់គ្លេស) ត្រូវមានបញ្ចូលការបកប្រែដែលត្រឹមត្រូវ ឬលិខិតបញ្ជាក់ ការបកប្រែជាភាសាអង់គ្លេស។

- ដីកាលែងលះ

ភាសាដែលប្រើនៅលើដីកាលែងលះ (ក្រៅពីភាសាអង់គ្លេស) ត្រូវមានបញ្ចូលការបកប្រែដែលត្រឹមត្រូវ ឬលិខិតបញ្ជាក់ការបកប្រែជាភាសាអង់គ្លេស។

- ឯកសារបរទេស រួមមាន៖
  - លិខិតឆ្លងដែនបរទេស
  - អត្តសញ្ញាណបណ្ណសញ្ជាតិបរទេស
  - បណ្ណស្ថានកុងស៊ុល
  - បណ្ណបើកបរបរទេស

ភាសាដែលប្រើនៅលើបណ្ណបើកបរបរទេស (ក្រៅពីភាសាអង់គ្លេស) ត្រូវមានបញ្ចូលការបកប្រែដែលត្រឹមត្រូវ ឬលិខិតបញ្ជាក់ការបកប្រែជាភាសាអង់គ្លេស។

- អត្តសញ្ញាណបណ្ណ

អត្តសញ្ញាណបណ្ណត្រូវមានរូបថតនៃអ្នកដាក់ពាក្យសុំ ប្រើប្រាស់ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ឬរដ្ឋាភិបាលនៅក្នុងសហរដ្ឋអាមេរិក។

- ឯកសារបញ្ជាក់កំណើតរួមមាន៖
  - សំបុត្រកំណើត
  - កំណត់ត្រាស្មុំកូន

ឯកសារណាមួយដែលមានបង្ហាញជូននៅក្នុងបញ្ជីខាងលើ ដែលមានឈ្មោះប្ដី/ប្រពន្ធ ដៃគូ កូន ឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់ ប្រសិនបើអ្នកដាក់ពាក្យសុំ ក៏ បានផ្ដល់ជូនផងដែរនូវសំបុត្រកំណើត កំណត់ត្រាស្មុំកូន សំបុត្រអាពាហ៍ពិពាហ៍ ឬលិខិតចុះបញ្ជីដៃគូ ដើម្បីកំណត់ពីទំនាក់ទំនង។

## តើខ្ញុំអាចទទួលបានលិខិតបរទេសដោយរបៀបណា?

ប្រសិនបើអ្នកត្រូវការផ្លាស់ប្ដូរ ឬទទួលបានឯកសារបរទេសរបស់អ្នក អ្នកអាចទំនាក់ទំនងស្ថានកុងស៊ុលប្រទេសរបស់អ្នក។ ការិយាល័យកុងស៊ុល ធ្វើការក្នុងនាមជាតិសាសន៍បរទេសដើម្បីផ្ដល់ជំនួយ និងជួយប្រជាជនរបស់គេដែលកំពុងរស់នៅក្រៅប្រទេស។

ទីតាំងស្ថានកុងស៊ុល និងព័ត៌មានទំនាក់ទំនងអាចមាន ការផ្លាស់ប្ដូរជាប្រចាំ។ ដើម្បីធានាថាអ្នកទទួលបានព័ត៌មានថ្មីបំផុតទាក់ទងនឹងស្ថានកុងស៊ុលរបស់អ្នក សូមចូលទៅកាន់ **state.gov** សម្រាប់ព័ត៌មានពេញលេញពីស្ថានកុងស៊ុលនៅក្នុង សហរដ្ឋអាមេរិក។

## ចុះប្រសិនបើអត្តសញ្ញាណបណ្ណ/ទីកន្លែងស្នាក់នៅរបស់ខ្ញុំមិនអាចផ្ទៀងផ្ទាត់បាន តើខ្ញុំត្រូវធ្វើដូចម្ដេច?

DMV នឹងខិតខំធ្វើគ្រប់បែបយ៉ាងដើម្បី ផ្ទៀងផ្ទាត់ អត្តសញ្ញាណបណ្ណ/ទីកន្លែងស្នាក់របស់អ្នក។ ប្រសិនបើ DMV មិនអាចធ្វើបែបនេះបាន គេនឹងផ្ញើលិខិតមួយច្បាប់ទៅអ្នកតាមប្រៃសនីយ៍ដើម្បីចាប់ផ្ដើមដំណើរការនៃការបញ្ជូនបន្តសម្រាប់ការ ត្រួតពិនិត្យបណ្ណបើកបរលើកទៅពីរ។ អ្នកមានសិទ្ធិស្នើសុំសវនការប្រសិនបើ DMV មិនអាចផ្ទៀងផ្ទាត់អត្តសញ្ញាណបណ្ណ/ទីកន្លែងស្នាក់បាន។ ប្រសិន បើមានការប្រគល់ឯកសារក្លែងក្លាយ DMV អាចនឹងចាត់វិធានការបន្ថែម។

## ព័ត៌មានអំពីអង្គភាព *DMV INV*

បុគ្គលិក INV របស់ DMV នឹងធ្វើដំណើរការនៃការត្រួតពិនិត្យលើកទីពីរ។ INV គឺជាអ្នកដឹកនាំការអនុវត្តច្បាប់ ជាមួយក្រុមជំនាញដែលមានមន្ត្រីអនុវត្តច្បាប់ប្រហែល 220 នាក់ និងបុគ្គលិកគាំទ្រច្រើនជាង 130 នាក់។ INV ធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹង ចោរកម្មអត្តសញ្ញាណ ឧក្រិដ្ឋកម្មហិរញ្ញវត្ថុ ការប្រព្រឹត្តិខុសរបស់និយោជិត ការក្លែងបន្លំ/ការកែប្រែឯកសារ និងពាក្យបណ្ដឹងអតិថិជនប្រឆាំងនឹង DMV និងអាជ្ញាបណ្ណវិជ្ជាជីវៈ។ បុគ្គលិក INV អនុវត្តសេវាពិសេសសម្រាប់អតិថជន តាមរយៈការផ្ដល់ជូនសេវាដែលមានគុណភាព ប្រកបដោយសុចរិតភាព ជំនាញវិជ្ជាជីវៈ និងការគោរពចំពោះនិយោជិត និងអតិថិជនទាំងអស់។